# រាជបណ្ឌិត្យសភាកម្ពុជា
## វិទ្យាស្ថានវប្បធម៌ និងវិចិត្រសិល្បៈ

*អត្ថបទស្រាវជ្រាវ ស្ដីពី*

# ប្រភេទកុលាលភាជន៍ផុយនៅស្ថានីយជើងឯក





*ដោយ៖ កញ្ញា* **តាកេត ស័កដា**

*មន្ត្រីស្ម័គ្រចិត្តនៃវិទ្យាស្ថានវប្បធម៌ និងវិចិត្រសិល្បៈ នៃរាជបណ្ឌិត្យសភាកម្ពុជា*

*ខែមករា ឆ្នាំ២០១៩*

# ប្រភេទកុលាលភាជន៍ផុយនៅស្ថានីយជើងឯក

ដោយៈ **កញ្ញា តាកេត ស័កដា**

មន្ត្រីស្ម័គ្រចិត្តនៃវិទ្យាស្ថានវប្បធម៌ និងវិចិត្រសិល្បៈ នៃរាជបណ្ឌិត្យសភាកម្ពុជា

## សេចក្តីផ្តើម

ការសិក្សាស្រាជ្រាវពីកុលាលភាជន៍ខ្មែរជាផ្នែកមួយដ៏សំខាន់ក្នុងវិស័យបុរាណវត្ថុវិទ្យា និងប្រវត្តិសាស្ត្រ ព្រោះតាមរយៈកុលាលភាជន៍ទាំងនោះ អ្នកស្រាវជ្រាវអាចកំណត់បានពីភាពប៉ិនប្រសប់របស់ជនជាតិខ្មែរក្នុងការផលិត និងរចនាកុលាលភាជន៍ ហើយអ្នកស្រាវជ្រាវអាចកំណត់អាយុកាលរបស់កុលាលភាជន៍ អាយុកាលរបស់ស្ថានីយ អាយុកាលនៃស្រទាប់ដី សេដ្ឋកិច្ចក្នុងតំបន់ ជីវភាពរបស់គ្រួសារ និងផ្នែកសំខាន់ៗជាច្រើនទៀតពាក់ព័ន្ធការប្រើប្រាស់ ដូចជាក្នុងពិធីសាសនា និងជំនួញជាដើម។ ការស្រាវជ្រាវកុលាលភាជន៍ចាប់ផ្តើមផុសផុលក្នុងរយៈពេលប៉ុន្មានទសវត្សរ៍ចុងក្រោយនេះ គឺចាប់ពីឆ្នាំ១៩៩៧ បន្ទាប់ពីមានការស្រាវជ្រាវរកឃើញស្ថានីយឡបុរាណមួយចំនួននៅតំបន់អង្គរ និងតំបន់ដទៃទៀត។ ការសិក្សាស្រាវជ្រាវពីកុលាលភាជន៍ភាគច្រើនមាននៅតំបន់អង្គរ ខេត្តសៀមរាប ពីកំណាយដែលគេប្រទះឃើញនៅស្ថានីយឡកុលាលភាជន៍ជាច្រើនរួមមាន ឡអន្លង់ធំ ឡតានី ឡសរសី ឡបាកោង ឡខ្នារពោធិ៍។ តាមការវិភាគអាយុកាលរបស់ឡកុលាលភាជន៍បង្ហាញឃើញថា ឡនៅតំបន់អង្គរចាប់ផ្តើមដំណើរការនៅដើមសម័យអង្គរចាប់ពីចុងសតវត្សរ៍ទី៩ រហូតដល់សតវត្សរ៍ទី១៣[1]។ ដោយឡែកការស្រាវជ្រាវនាពេលថ្មីនេះបង្ហាញថា នៅ**ស្ថានីយជើងឯក** នៅភាគខាងត្បូងរាជធានីភ្នំពេញ ក៏មានឡដុតកុលាលភាជន៍ ដូចនៅតំបន់អង្គរដែរ[2]។ ការសិក្សាស្រាវជ្រាវដោយលោកបណ្ឌិត ផុន កសិកា ក្នុងឆ្នាំ២០០៧ បានរកឃើញថា ឡដុតកុលាលភាជន៍

---

[1] Ea Darith, 2010, Angkorian Stoneware Ceramics: The Evolution of Kiln Structure and Ceramic Typology, The Dissertation Submitted in Partial Fulfillment of The Requirements for The Degree of Doctor of Philosophy. p. 216-219

[2] Phon Kaseka, 2004, Phnom Borei and Its Relationship to Angkor Borei, Report submitted to the Ministry of Culture and Fine Arts, Phnom Penh. p. 48-50

ផុយ និងផលិតផលកុលាលភាជន៍ផុយ មាននៅស្ថានីយជើងឯក ដែលសង់និងផលិតនៅសតវត្សទី ៥[3]។




រូបលេខ១៖ ស្ថានីយជើងឯកស្ថិតនៅត្បូងរាជធានីភ្នំពេញ

អត្ថបទនេះនឹងធ្វើការបកស្រាយពីទម្រង់ និងប្រភេទនៃបំណែកកុលាលភាជន៍ផុយមួយចំនួនដែលបានរកឃើញក្នុងកំណាយនៅស្ថានីយជើងឯកកាលពីឆ្នាំ២០០៧ ដោយបណ្ឌិត ផុន កសិកា តែប៉ុណ្ណោះ លើបំណែកសរុបចំនួន ៧ ២៣១ នៃកុលាលភាជន៍ប្រភេទកុណ្ឌី ឆ្នាំង ក្អម ក្រឡ ខ្ទះ ថូ ចាន...។ ក្នុងបំណែកទាំងនោះមានបំណែកមាត់ ចំពួយ ក្អេង ខ្លួន និងបាតចំនួន ២ ១៤៩បំណែកដែលបានដឹងរូបរាងបានច្បាស់ និងបំណែកមួយចំនួនទៀតមានរូបរាងប្រហាក់ប្រហែលគ្នាដែរ តែយើងពិបាកក្នុងការបែងចែកដាច់ពីគ្នាច្បាស់ គ្រាន់ដឹងថាជាបំណែកក្អម ឆ្នាំង ក្រឡ ថូ ខ្ទះ ចាន កូនតែង។ល។

ការសិក្សានេះ យើងជ្រើសរើសយកមកវិភាគរូបរាងនិងប្រភេទ ដោយជ្រើសយកតែរូបរាងមាត់ បាត និងចំពួយនៃកុលាលភាជន៍មកគូរគំនូរតាមប្រព័ន្ធកុំព្យូទ័រ (Adobe Illustrator) និងការធ្វើការ

---

[3] ផុន កសិកា, ២០១៨, ឡ និងកុលាលភាជន៍នៅស្ថានីយជើងឯក, និក្ខេបបទបណ្ឌិត ឯកទេសបុរាណវិទ្យា, រាជបណ្ឌិត្យសភាកម្ពុជា, ទំ. ៩១-៩៦

បែងចែកទៅតាមប្រភេទនៃភាជន៍នីមួយៗ រួមមាន កុណ្ឌី ផ្ដាំង ក្អម ក្រឡ ខ្ចូច ថូ ចាន និងពែងសិតលោហៈ។

## ១. កុណ្ឌី

ពាក្យកុណ្ឌីក្នុងសិលាចារឹកខ្មែរមានប្រភពដើមពីសំស្ក្រឹត kuntikā និង kunti ដែលសំដៅទៅលើភាជន៍មានចំពួយសម្រាប់ប្រើក្នុងកិច្ចសាសនា។ កុណ្ឌីមានខ្លួនធំ និងក្អេងប៉ោង មានចំពួយវែង។

ស្ថានីយជើងឯកគឺជាស្ថានីយផលិតកុលាលភាជន៍ផុយ ជាពិសេសផលិតកុណ្ឌីក្នុងប្រទេសកម្ពុជា ក៏ដូចជាតំបន់អាស៊ីអាគ្នេយ៍។ តាមរយៈចំនួននៃបំណែកកុណ្ឌីដែលបានរកឃើញ ភាគរយនៃចំនួនកុណ្ឌីមានចំនួន៣០%នៃចំនួនបំណែកកុលាលភាជន៍ទាំងអស់។ ទិន្នន័យនេះបង្ហាញថាស្ទូននៅជើងឯកមានជំនាញផលិតកុណ្ឌីក្នុងបរិមាណច្រើន[4]។ ការសិក្សាស្រាវជ្រាវបុរាណវិទ្យា បានរកឃើញថា នៅតំបន់អាស៊ីអាគ្នេយ៍ ផលិតកម្មកុណ្ឌីផលិតកុណ្ឌីក្នុងស្រុកផ្ទាល់តែម្ដង ដោយមិនចាំបាច់នាំចូលពីប្រទេសឥណ្ឌាឡើយ[5]។ ទោះយ៉ាងណា កន្លងមកមិនទាន់មានភ័ស្តុតាងស្ថានីយឡផលិតកុលាលភាជន៍រកឃើញផ្សេងពីក្នុងតំបន់នេះនៅឡើយទេ[6]។



រូបលេខ២៖ រូប  និងគំនូរកុណ្ឌីជួសជុលរួច បន្ទាប់ជីកបានពីកំណាយនៅឆ្នាំ២០១៧

[4] ផុន កសិកា៖ លទ្ធផលកំណាយនៅស្ថានីយបន្ទាយមូលជើងឯក, ២០១៤, ទំ. ២៤

[5] ផុន កសិកា៖ លទ្ធផលកំណាយនៅស្ថានីយបន្ទាយមូលជើងឯក, ២០១៤, ទំ. ២៤

៦ ចាប សោភារ៉ា និងឆាយ វិសុទ្ធ៖  ភាជន៍ដីផុតផលិតនៅភូមិដំណាក់ចំបក់, ឧទ័យ លេខ៩, ២០០៨, ទំ. ១៣៣

## ២. ឆ្នាំង

ឆ្នាំងស្ថិតក្នុងក្រុមកុលាលភាជន៍មួយដែលប្រើសម្រាប់ដាំស្ល មានមាត់បត់រមូរចេញក្រៅជាគែម[7] ថែមទាំងមានគម្រប[8]។ ឆ្នាំងជាធម្មតាមានខ្លួនមូល កខ្ពស់ ទំហំមាត់តូចងាយស្រួលក្នុងការចាប់កាន់។ ឆ្នាំងមានក្បាច់ត្រង់ផ្ទៃបាត ខ្លួន និងក្អែង។ មនុស្សប្រើសម្រាប់ដាំស្លម្ហូបអាហារ ដាំទឹក ឬដាំថ្នាំជាដើម។ ក្នុងបំណែកឆ្នាំងដែលជ្រើសមកគូមានចំនួន៣០ដុំ ក្នុងនោះមានទម្រង់៦ប្រភេទខុសគ្នា មានឆ្នាំងកខ្លី និងកវែង ខ្លះមានកម្រាស់ស្តើង ខ្លះមានកម្រាស់ក្រាស់។ ឆ្នាំងដែលបានប្រទះឃើញភាគច្រើនជាឆ្នាំងប្រភេទទី៣ ដែលជាប្រភេទឆ្នាំងកខ្លី មាន១៥បំណែក ក្រៅពីនោះប្រភេទទី១មានចំនួន៣បំណែក ប្រភេទទី២មាន២បំណែក ប្រភេទទី៤មាន៣បំណែក ប្រភេទទី៥មាន៤បំណែក ប្រភេទទី៦មាន៣បំណែក។ បាតមានចំនួន២បំណែក មាន២ទម្រង់។




រូបលេខ៣៖ រូប និងគំនូរឆ្នាំងមានបាតក្រលោម

## ៣. ក្អម

ក្អមជារបស់ធ្វើពីដីសម្រាប់ដាក់ទឹក មានកស្តួច រាងធំក្អែង ដូចផ្លែឃ្លោកសាយដៀវ[9]។ ក្អមខ្លះមានរូបរាងប្រហែលនឹងឆ្នាំងដែរ ប៉ុន្តែក្អមមានកវែងជាងឆ្នាំង និងគ្មានចំនៀរ[10]ខាងក្នុងមាត់ដូចឆ្នាំងឡើយ។ នៅផ្នែកខាងក្នុងនៃមាត់ក្អមគឺរលោង មានរាងកោងបើកមាត់ឡើង។ បំណែកមាត់ក្អមដែលជ្រើសយកមកគូមានចំនួន៧បំណែក មាន៣ទម្រង់៖ ទម្រង់ទី១មាន២បំណែកជាក្អមមាត់រាងជ្រុងស្មើ

[7] ស្មូនឆ្នាំងនៅតំបន់ខេត្តកំពង់ឆ្នាំងហៅគែមមាត់ឆ្នាំងថា "ជំនៀរ"។

[8] Groslier៖ ផ្តើមសិក្សាអំពីកុលាលភាជន៍នៅអង្គរ, បកប្រែដោយ អាំង ជូលាន ក្នុងទស្សនាវដ្តី ឧទ្ទ័យ លេខ១, ២០០០, ទំ. ១៥៨-១៥៩

[9] វចនានុក្រមខ្មែរ, ការផ្សាយរបស់វិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យជំនាន់ទី៥, ១៩៧៣

[10] ស្មូនឆ្នាំងនៅខេត្តកំពង់ឆ្នាំងហៅ "ចំនៀរ" សំដៅលើគែមខាងក្នុងនៃមាត់ឆ្នាំង។

បំណែក ទម្រង់ទី២មាន២បំណែកដូចគ្នាជាក្អមមានមាត់បញ្ចិតចូលក្នុងដូចប្រភេទឆ្នាំងកខ្ចីនិងទម្រង់ទី៣មាន៣បំណែកជាក្អមមានមាត់ធំ និងមានរាងមូលស្រដៀងនឹងមាត់ឆ្នាំងរាងមូល។ តាមការអង្កេតគ្រប់បំណែកភាជន៍ក្អម បានឱ្យដឹងថាបំណែកមាត់ក្អមដែលសម្បូរជាងគេគឺ ក្អមទម្រង់ទី៣។



រូបលេខ២៤៖ រូប និងគំនូរបំណែកក្អម

## ៤. ក្រឡ

ក្រឡជាភាជន៍ប្រើប្រាស់ប្រចាំថ្ងៃដូចឆ្នាំង និងប្រភេទកុលាលភាជន៍ផ្សេងៗទៀតដែរ មានសណ្ឋានដូចពាង តែតូចជាង ធ្វើដោយដីដូចគ្នា[11]។ ជាទូទៅ ក្រឡមានរាងមូលទ្រវែង មានបាតរាបស្មើ ប្រហែលនឹងថូដែរ។ ក្រឡមានកខ្ចី និងមាត់បើក ប្រហែលគ្នានឹងមាត់ក្អម។ ក្រឡដែលកំណាយបានក្នុងឆ្នាំ២០០៧មានចំនួនតិចបំផុតតែមានរូបរាងស្ទើរតែពេញលេញ រូបនៅក្នុងគំនូរមានចំនួន២បំណែក ១បំណែកជាមាត់ និង១បំណែកទៀតជាបាតក្រឡ។



រូបលេខ២៥៖ រូបគំនូរមាត់ និងបាតក្រឡ

[11] វចនានុក្រមខ្មែរ, ការផ្សាយរបស់វិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យជំនាន់ទី៩, ១៩៧៣

## ៥. ខួច

ខួចគឺជាដបតូចមូល មាត់តូច ធ្វើដោយដី[12]។ តាមការសិក្សាស្រាវជ្រាវនៅតំបន់អង្គរ គេបានរកឃើញខួចច្រើន និងមានរូបរាងខុសៗគ្នា។ តាមរយៈការសិក្សាស្រាវជ្រាវ និងកំណាយនៅឆ្នាំ ២០០៧ កន្លែងមកនៅស្ថានីយជើងឯក គេរកឃើញខួចតែមួយគត់ ដែលមានរូបរាងពេញលេញ មានទំហំតូច មានកស្មើត្រង់ជាមួយមាត់នៅគន្ទាក់កមានឆ្នូតតូចជុំវិញ នៅផ្ទៃពាក់កណ្តាលខ្លួនមានផតចូលបន្តិចព័ទ្ធជុំវិញ ផ្នែកបន្ទាប់មានរាងស្តួចចូលក្នុង ទើបកាច់រាងចេញក្រៅវិញជាបាតរបស់ខួច។ តាមការអង្កេតរូបរាង ខួចប្រហែលជាមានគម្រប ព្រោះខួចគឺអាចជាដបម្យ៉ាង កាលណាជាដបអាចមានគម្រប។




រូបលេខ៦៖ រូប និងគំនូរខួចរូបរាងតូច

## ៦. ថូ

ថូជាប្រដាប់សម្រាប់ដាក់ទឹកមានសណ្ឋានដូចជាថោ ក៏ប៉ុន្តែវាមានក ហើយមានគម្របដូចជាផ្ទុក[13]។ ថូមានតែមួយទម្រង់ មានទំហំនិងរូបរាងស្រដៀងនឹងកុណ្ឌី និងក្រឡដែរ ក៏ប៉ុន្តែមានកត្រង់ស្មើជាមួយមាត់ដូចខួច  ហើយនៅត្រង់បាតមានរាងតូចប្រហែល៦ស.ម និងមានគន្ទាក់ឆ្នូតតូចនៅជុំវិញ (រូបទី៧)។ ថូអាចនឹងងាយច្រឡំជាមួយក្រឡណាស់ តែថូមានមាត់តូច កត្រង់ ក្អែងរាងធ្លាក់មិនប៉ោងដូចក្រឡ  ហើយក៏មានលក្ខណៈស្រដៀងនឹងកុណ្ឌីដែរ  ដោយគ្រាន់តែកុណ្ឌីមានក្អែងបំប៉ោង និងមានចំពួយសម្រាប់ចាក់ទឹក។

---

[១២] វចនានុក្រមខ្មែរ, ការផ្សាយរបស់វិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យជំនាន់ទី៥, ១៩៧៣

[១៣] វចនានុក្រមខ្មែរ, ការផ្សាយរបស់វិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យជំនាន់ទី៥, ១៩៧៣




រូបលេខ៧៖ រូបថូស្មើរតែពេញលេញ ដែលបានជួសជុលផ្គុំ

## ៧. ចាន

ចានជាវត្ថុ ឬភាជន៍មួយបែបមានប្រភេទផ្សេងៗគ្នា មានរាងក្រឡោមសំប៉ែត សម្រាប់ដាក់ខាទនីយហារ[14]។ ចានជាសម្ភារៈប្រើប្រាស់ប្រចាំថ្ងៃដូច ឆ្នាំង ក្អម ក្រឡដែរ។ កំណាយបានប្រទះឃើញបំណែកចានតែ២បំណែក។ បំណែកទី១ មាត់ចាន បំណែកទី២បាតចានមានកម្រាស់ស្តើង។



រូបលេខ៨៖   រូបគំនូរបំណែកមាត់ និង

## ៨. ពែងសិតលោហៈ

ពែងសិតលោហៈជាប្រភេទកុលាភាជន៍មានទំហំតូច មានបាតរាបស្មើ និងមាត់បើកធំ។ គេប្រើពែងសិតលោហៈសម្រាប់ប្រើប្រាស់ជាពុម្ពចាក់លោហៈបន្ទាប់ពីរំលាយរួច។ កំណាយស្រាវជ្រាវឡើនៅស្ថានីយជើងឯកឆ្នាំ២០០៧ ក៏បានរកឃើញពែងស្មិតលោហៈមួយចំនួនដែរ។ ដោយសារពែង

[១៤] វចនានុក្រមខ្មែរ, ការផ្សាយរបស់វិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យជំនាន់ទី៩, ១៩៧៣

សិតលោហៈមានទំហំតូចពេកទើបធ្វើឱ្យខូចខាតបាត់បង់រូបរាង និងមានការលំបាកក្នុងការគូរ។ ពែងស្និតលោហៈមានចំនួន២បំណែកដែលនៅមានរូបរាងសេសសល់ដែលអាចគូរ ចេញជារូបរាងទាំងមូលឡើងវិញបានដែលមានទំហំស្មើរដូចគ្នា តែមានរូបរាងខុសគ្នាបន្តិច ដោយទម្រង់ទី១មានរូបរាងរាងជ្រុង និងទម្រង់ទី២មានរូបរាងមូល។



រូបលេខ៩៖ កូនពែងសិតលោហៈដែលមានរូបរាងពេញលេញ

## សន្និដ្ឋាន

តាមរយៈការសិក្សាវិភាគកុលាលភាជន៍ផុយនៅស្ថានីយជើងឯកបានបង្ហាញថា ស្មូននៅស្ថានីយជើងឯកមានបច្ចេកទេសផលិតកុលាលភាជន៍ច្បាស់លាស់មានសមត្ថភាពផលិតកុលាលភាជន៍ទៅតាមប្រភេទផ្សេងៗគ្នា។ កុលាលភាជន៍ប្រភេទផ្សេងៗត្រូវបានផលិតទៅតាមតម្រូវការរបស់អ្នកប្រើប្រាស់ ទាំងសម្រាប់ការប្រើប្រាស់ក្នុងជីវិតរស់នៅប្រចាំថ្ងៃ និងសម្រាប់ក្នុងពិធីសាសនា។ ប្រភេទថ្នាំង ចាន ក្អម ក្រឡ និងថូ ជាប្រភេទដែលគេប្រើក្នុងជីវិតប្រចាំថ្ងៃ ជាជាងសម្រាប់ក្នុងពិធីសាសនា។ លក្ខណៈពិសេសមួយទៀត ថ្នាំងគឺជាប្រភេទមួយតម្រូវឱ្យផលិតជាកុលាលភាជន៍ផុយ ព្រោះអាចយកទៅចម្អិនអាហារបានទោះជាស្ល ឬដាំក៏ដោយ។ មានប្រភេទកុលាលភាជន៍ខ្លះផលិត ជាកុលាលភាជន៍ផុយផង និងកុលាលភាជន៍រឹងផង ដូចជា ក្រឡ ចាន ក្អម និងថូ។ ខុសពីប្រភេទផ្សេងៗទៀត ថ្នាំងមិនអាចផលិតជាកុលាលភាជន៍រឹងបានទេ ដោយសារកុលាលភាជន៍រឹងមិនយកយកទៅចម្អិនអាហារបាន។ ចំពោះប្រភេទដែលគេប្រើប្រាស់ក្នុងពិធីសាសនាមានប្រភេទដូចជា កុណ្ឌី ខួច។ កុណ្ឌីជាប្រភេទកុលាលភាជន៍ពិសេសប្រើក្នុងពិធីសាសនាក្នុងសម័យបុរាណទាំងក្នុងប្រទេសកម្ពុជា

*និងតំបន់អាស៊ីអាគ្នេយ៍ទាំងមូល។ វត្តមានកុណ្ឌីអាចបង្ហាញថា ស្ថានីយជើងឯកជាស្ថានីយពិសេសមួយ ដែលចេះផលិតកុណ្ឌីតាំងពីសតវត្សរ៍ទី៥នៃគ្រិស្តសករាជ។ បច្ចេកទេសនៃការផលិតកុលាលភាជន៍នៅជើងឯក បានវិវឌ្ឍពីផលិតកម្មកុលាលភាជន៍ផុយដល់ផលិតកម្មកុលាលភាជន៍រឹងនៅសតវត្សរ៍ក្រោយៗមកទៀត។*

*ការសិក្សាស្រាវជ្រាវធ្វើកំណាយនៅស្ថានីយឡកុលាលភាជន៍ផុយនៅជើងឯកគួរតែត្រូវអនុវត្តបន្ថែមទៀត ដើម្បីសិក្សាស្វែងយល់ពីប្រភេទកុលាលភាជន៍ផុយ និងស្វែងរកទិន្នន័យពាក់ព័ន្ធនឹងភស្តុតាងបុរាណវត្ថុវិទ្យាផ្សេងៗទៀត៕*

## គន្ថនិទ្ទេស


ឆាយ វិសុទ្ធ, ចាប សោភារ៉ា

២០០៨, *ភាជន៍ដីដុតផលិតនៅភូមិដំណាក់ចំបក់,* ឧទ័យ លេខ៩

ជួនណាត

១៩៧៣, វចនានុក្រមខ្មែរ, ការផ្សាយរបស់វិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យជំនាន់ទី៥

ផុន កសិកា

២០១៤, *លទ្ធផលកំណាយនៅស្ថានីយបន្ទាយមូលជើងឯក,* របាយការណ៍សម្រាប់ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ និងរាជបណ្ឌិត្យសភាកម្ពុជា, ភ្នំពេញ

២០១៨, ឡ និងកុលាលភាជន៍នៅស្ថានីយជើងឯក, និក្ខេបបទបណ្ឌិត ឯកទេសបុរាណវិទ្យា រាជបណ្ឌិត្យសភាកម្ពុជា

EA, Darith

2010, Angkorian Stoneware Ceramics: The Evolution of Kiln Structure and Ceramic Typology, The Dissertation Submitted in Partial Fulfillment of The Requirements for The Degree of Doctor of Philosophy.

GROSSLIER, B. P.

២០០០, *ផ្តើមសិក្សាអំពីកុលាលភាជន៍នៅអង្គរ,* បកប្រែដោយ អាំង ជូលាន ក្នុងទស្សនាវដ្តី ឧទ្ទ័យ លេខ១

PHON, Kaseka

2004, Phnom Borei and Its Relationship to Angkor Borei, Report submitted to the Ministry of Culture and Fine Arts, Phnom Penh.